អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# កូនជ្រូកទាំងបី
# Three little pigs

កែសម្រួលដោយ **TUKTUK**

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន





« កូនសម្លាញ់ទាំងបី ឥឡូវកូនធំៗអស់ហើយកូនៗត្រូវរៀនរស់នៅដោយខ្លួនឯង ព្រោះម៉ែមិនអាចចិញ្ចឹមកូនៗទាំងបីបានទៀតនោះទេ។ ម៉ែនឹងឱ្យប្រាក់ខ្លះដល់កូនៗ ដើម្បីធ្វើដំណើរតាមផ្លូវទៅរកកន្លែងសង់ផ្ទះរស់នៅដោយខ្លួនឯង » ម៉ែនិយាយ។





« បាទ! ម៉ែ » កូនជ្រូកទាំងបីឆ្លើយ។
កូនជ្រូកទីមួយនិងទីពីរបានសម្រេចចិត្តរស់នៅបែកគ្នា ប៉ុន្តែកូនជ្រូកទីបីមិនសប្បាយចិត្តទេ ព្រោះវាគិតថា ការរស់នៅជុំគ្នាគឺជាសាមគ្គីភាពដ៏រឹងមាំនិងមានសុវត្ថិភាព។





ថ្ងៃបន្ទាប់ កូនជ្រូកទាំងបីចាប់ផ្ដើមស្វែងរកទិញវត្ថុធាតុដើមនិងបោះទីតាំងសង់ផ្ទះរៀងៗខ្លួន។ កូនជ្រូកទីមួយបានសង់ផ្ទះពីចំបើង ព្រោះគិតថាអាចសន្សំប្រាក់បានខ្លះនិងងាយស្រួលសង់ទៀតផង។វាបានសង់ផ្ទះរួចមុនគេ ហើយគិតថា ខ្លួនជាកូនជ្រូកដែលឆ្លាត។





កូនជ្រូកទីពីរសង់ផ្ទះអំពីឈើ ព្រោះផ្ទះឈើត្រជាក់និងសង់អស់ប្រាក់តិច។
វាគិតថា ហេតុអ្វីបានជាកូនជ្រូកទីមួយសង់ផ្ទះលឿនម្ល៉េះ?
ផ្ទះឈើរបស់វារឹងមាំជាងផ្ទះកូនជ្រូកទីមួយដែលសង់ពីចំបើង។





ចំណែកកូនជ្រូកទីបីគិតថា ត្រូវតែសង់ផ្ទះរឹងមាំមួយអំពីថ្ម ដើម្បីការពារសុវត្ថិភាព ទោះបីជាចំណាយពេលវេលាយូរនិងត្រូវដេកលើដីសិនក៏ដោយ។
បងៗរបស់វាបានសង់ផ្ទះរួចមុន ហើយបានសើចចំអកឱ្យកូនជ្រូកទីបី។
កូនជ្រូកទីបីមិនខ្វល់ នៅតែបន្តសង់ផ្ទះរបស់វាដដែល។





ច្រើនថ្ងៃកន្លងផុតទៅ កូនជ្រូកទាំងបីរស់នៅយ៉ាងសុខសាន្ត។
ថ្ងៃមួយ ឆ្កែចចកឃើញកូនជ្រូកទាំងបី ហើយវានិយាយ
« អូ! កូនជ្រូកនោះមើលទៅគួរឱ្យចង់ស៊ីដល់ហើយ ខ្ញុំចង់ស៊ីពួកវាជាអាហារ។
ខ្ញុំឃ្លាន! ឃ្លានខ្លាំងណាស់! »





ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីមួយ « បើកទ្វារ! បើកទ្វារ! បើកទ្វារ! »
ដើម្បីសុំចូលក្នុងផ្ទះ តែកូនជ្រូកមិនព្រម។
កូនជ្រូកទីមួយនិយាយ « មុខឯងអាក្រក់ណាស់ មានរោមពេញមុខ ចង្កូមវែងៗ
គួរឱ្យខ្លាច ឆាប់ចេញទៅ »។ ឆ្កែចចកខឹងក៏បានបឺតខ្យល់ចូលពេញពោះ
ហើយផ្លុំផ្ទះរបស់កូនជ្រូកទីមួយប៉ើងគ្មានសល់។





កូនជ្រូកទីមួយក៏រមៀលចូលក្នុងផ្ទះឈើរបស់កូនជ្រូកទីពីរ។
ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីពីរ « បើកទ្វារ! បើកទ្វារ! បើកទ្វារ! »
ដើម្បីសុំចូលក្នុងផ្ទះ តែកូនជ្រូកមិនព្រម។
កូនជ្រូកទីពីរនិយាយ « មុខឯងអាក្រក់ណាស់ មានរោមពេញមុខ ចង្កូមវែងៗ
គួរឱ្យខ្លាច ឆាប់ចេញទៅ »។ ឆ្កែចចកខឹងក៏បានបឺតខ្យល់ចូលពេញពោះ
ហើយផ្លុំផ្ទះឈើរបស់កូនជ្រូកទីពីរប៉ើងគ្មានសល់។





កូនជ្រូកទីមួយនិងកូនជ្រូកទីពីរបានរត់យ៉ាងលឿនចូលទៅក្នុងផ្ទះរបស់កូនជ្រូកទីបី។
កូនជ្រូកទីបីសួរ « តើមានរឿងអ្វីកើតឡើង ហេតុអ្វីបានជាបងៗភ័យខ្លាំងម្ល៉េះ? »
« ឆ្កែចចកបានផ្លុំផ្ទះរបស់ពួកយើងប៉ើងអស់ វានឹងមកផ្លុំផ្ទះរបស់ឯងឥឡូវដែរហើយ »។
« អូ! កុំបារម្ភណ៍អីបងៗ ឆ្កែចចកមិនអាចផ្លុំផ្ទះរបស់ខ្ញុំប៉ើងបានទេ »។





ឆ្កែចចកបានគោះទ្វារផ្ទះកូនជ្រូកទីបី « បើកទ្វារ! បើកទ្វារ! បើកទ្វារ! »
ឆ្កែចចកផ្លុំផង រត់បុកទ្វារផង រហូតវាអស់កម្លាំង នៅតែមិនបើុង
ព្រោះកូនជ្រូកទាំងបីបានឈរទប់ទ្វារយ៉ាងស្វាហាប់។
« អ្ហូ! ខ្ញុំនឹងរកមធ្យោបាយ ដើម្បីស៊ីពួកឯងឱ្យទាល់តែបាន »។





ឆ្មាចចកឡើងលើដំបូលផ្ទះចូលតាមបំពង់ផ្សែង។
ចំណែកកូនជ្រូកទាំងបីបានពិភាក្សាគ្នា តើពួកគេគួរធ្វើដូចម្តេច?





កូនជ្រូកទីបីនិយាយ « ខ្ញុំនឹងដុតភ្លើងដាំទឹក ដើម្បីឱ្យឆ្កែចចកធ្លាក់មក »។





ឆ្កែចចកបានរំកិលចូលតាមបំពង់ផ្សែងម្តងបន្តិចៗ
ក៏រអិលធ្លាក់ចូលក្នុងឆ្នាំងទឹកក្តៅរលាកស្លាប់បាត់ទៅ។





កូនជ្រូកទីមួយនិយាយ « អរគុណប្អូនដែលបានជួយបង ពួកយើងត្រូវតែសាមគ្គីគ្នាទើបរឹងមាំ »។
រីឯកូនជ្រូកទីពីរ « មែនហើយ! បើគ្មានឯង បងក្លាយជាចំណីឆ្កែចចក់បាត់ទៅហើយ »។
ការចេះជួយគ្នាក្នុងគ្រាមានអាសន្ន គឺជាសាមគ្គីភាពដ៏រឹងមាំ ហើយចាប់តាំងពីពេលនោះមក
កូនជ្រូកទាំងបីក៏រស់នៅជាមួយគ្នាយ៉ាងមានក្ដីសុខ៕






# កូនជ្រូកទាំងបី

កែសម្រួលដោយ TukTuk

រូបភាពដោយ និស្សិតនៃសកលវិទ្យាល័យ
Seinan Jo Gakuin ប្រទេសជប៉ុន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

TUKTUK

Rotary